


# ផលិតផលធានារ៉ាប់រងបន្ថែមលើជំងឺធ្ងន់ធ្ងរ

យើងតែងតែសង្ឃឹមថា គ្មានអ្វីនឹងកើតឡើងចំពោះយើងនោះទេ មិនថាជាបញ្ហាផ្នែកសុខភាព ឬបញ្ហាផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងមិនអាចដឹងមុននូវអ្វីដែលនឹងកើតឡើងនៅថ្ងៃស្អែកបានឡើយ។ ដោយហេតុនេះហើយ យើងគួររៀបចំផែនការដើម្បីប្រឈមមុខជាមួយនឹងជំងឺធ្ងន់ធ្ងរណាមួយដែលកើតឡើង ពីព្រោះវាអាចធ្វើឲ្យយើងបាត់បង់ប្រាក់ដែលយើងខិតខំសន្សំទុកសម្រាប់ថ្ងៃអនាគត។

“ផលិតផលធានារ៉ាប់រងបន្ថែមលើជំងឺធ្ងន់ធ្ងរ” ផ្តល់ជូនអ្នកនូវកញ្ចប់ទឹកប្រាក់ធានារ៉ាប់រង ក្នុងករណីអ្នកបានធ្វើរោគវិនិច្ឆ័យឃើញថាមានស្ថានភាពជំងឺណាមួយក្នុងចំណោមជំងឺទាំង 26 ប្រភេទ ដោយរួមមាន ជំងឺមហារីក ជំងឺខួរក្បាល ជំងឺថ្លើម ជំងឺសួត ជំងឺតម្រងនោម ជំងឺបេះដូង និងជំងឺផ្នែកប្រព័ន្ធសរសៃឈាម ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយព្រមទាំងការផ្លាស់ប្តូរសរីរាង្គសំខាន់ៗផងដែរ។ ជាមួយនឹងទឹកប្រាក់ផ្តល់ជូនរហូតដល់ 50% សម្រាប់ជំងឺដំណាក់កាលដំបូង អ្វីដែលអ្នកគួរផ្តោតសំខាន់នោះ គឺការមើលថែទាំខ្លួនឲ្យបានឆាប់ជាសះស្បើយ ជាជាងព្រួយបារម្ភអំពីការចំណាយទៅលើការព្យាបាលរបស់អ្នក។

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត

ព័ត៌មានសង្ខេបស្តីពី
ផលិតផលធានារ៉ាប់រងបន្ថែម

# អត្ថប្រយោជន៍សង្ខេប

ព្រឹត្តិការណ៍ដែលត្រូវបានធានា និងអត្ថប្រយោជន៍ដែលត្រូវទទួលបាន÷

| ព្រឹត្តិការណ៍ | នៃទឹកប្រាក់ធានារ៉ាប់រង |
|---|---|
| ជំងឺ/ ការវះកាត់ ក្រុមទី 2 | 100% |
| ជំងឺ/ ការវះកាត់ ក្រុមទី 1 | រហូតដល់ 50% |

សម្គាល់÷ ចំនួនទឹកប្រាក់សរុបដែលនឹងបង់ជូននៅក្រោម ជំងឺ/ ការវះកាត់ក្រុមទី 1 និងជំងឺ/ ការវះកាត់ក្រុមទី 2 មិនត្រូវលើស 100% នៃទឹកប្រាក់ធានារ៉ាប់រងសម្រាប់ “ផលិតផលធានារ៉ាប់រងបន្ថែមលើជំងឺធ្ងន់ធ្ងរ”។

# លក្ខខណ្ឌទទួលយកការការពារ

- ✓ ចាប់ពីអាយុ 18 ឆ្នាំ ដល់ 60 ឆ្នាំ។
- ✓ ជ្រើសរើសទទួលយកការការពារជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋានណាមួយរបស់ក្រុមហ៊ុន AIA ដែលអាចភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងបន្ថែមនេះ។

# ករណីមិនធានាសំខាន់ៗ

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើ÷

(i) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថាជាជំងឺ/ ការវះកាត់ក្រុមទី 1 ត្រូវបានបង្ហាញឱ្យឃើញមុន ឬក្នុងកំឡុងពេល 120 ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ

(ii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថាជា ជំងឺ/ ការវះកាត់ក្រុមទី 2 បានកើតឡើងមុន ឬក្នុងកំឡុងពេល 90 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ

(iii) អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬប្រយោលពីស្ថានភាពមុនពេលធានារ៉ាប់រងដូចបានកំណត់ ដែលកើតមាន មុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ

(iv) អាការៈជំងឺធ្ងន់ធ្ងរ ដែលតាមគំនិតរបស់យើងខ្ញុំ កើតមានដោយផ្ទាល់ ឬដោយប្រយោលពីវត្តមាននៃមេរោគអេដស៍ (AIDS ឬ HIV) និងលក្ខខណ្ឌផ្សេងៗដែលពាក់ព័ន្ធ ឬ

(v) អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលកើតឡើងដោយសារការធ្វើឱ្យរបួសខ្លួនឯង ឬ

(vi) អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលកើតឡើងដោយផ្ទាល់ពីការពិសារគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសកម្រិត ឬ

(vii) អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលបណ្តាលមកពីស្ថានភាពផ្លូវកាយ ឬផ្លូវចិត្តដែលបានកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ

(viii) ការបរិច្ចាគផ្នែកណាមួយនៃរាងកាយរបស់អ្នកដែលត្រូវបានធានារ៉ាប់រង។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ៗខ្លះៗប៉ុណ្ណោះ។ សូមពិនិត្យមើលករណីមិនធានាលម្អិតទាំងស្រុង ក្នុងបណ្ណសន្យារ៉ាប់រងរបស់អ្នក។

# ឧទាហរណ៍



កញ្ញា បុប្ផា អាយុ 35 ឆ្នាំ ជាវេជ្ជបណ្ឌិតផ្នែកជំងឺមហារីក និងមានឪពុកម្ដាយនៅក្រោមបន្ទុក។ ដើម្បីឱ្យប្រាកដថា ឪពុកម្ដាយរបស់នាងនឹងមិនជួបវិបត្តិហិរញ្ញវត្ថុ ក្នុងករណីមានគ្រោះអកុសលណាមួយកើតឡើងចំពោះនាង នាងបានជ្រើសយកផលិតផលធានារ៉ាប់រងមូលដ្ឋានរបស់ក្រុមហ៊ុន AIA ជាមួយទឹកប្រាក់ធានារ៉ាប់រងចំនួន US$ 100,000។

ដោយសារ កញ្ញា បុប្ផា ដឹងថាថ្លៃចំណាយសម្រាប់ព្យាបាលនៃជំងឺមហារីក ឬជំងឺធ្ងន់ធ្ងរមានតម្លៃថ្លៃ ហេតុនេះហើយ នាងបានសម្រេចចិត្តទទួលយកការការពារបន្ថែមពី "ផលិតផលធានារ៉ាប់រងបន្ថែមលើជំងឺធ្ងន់ធ្ងរ" ជាមួយទឹកប្រាក់ធានារ៉ាប់រងចំនួន US$ 50,000។

## អត្ថប្រយោជន៍ដែល កញ្ញា បុប្ផា និងក្រុមគ្រួសារទទួលបាន៖



**ករណីទី 1 ៖ កញ្ញា បុប្ផា បានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរ ដូចបានកំណត់ក្រោមជំងឺ/ការវះកាត់ ក្រុមទី 1 ក្នុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង**

កញ្ញា បុប្ផា នឹងទទួលបានសំណង ចំនួន US$ 25,000 មុន ដើម្បីឱ្យនាងមានប្រាក់គ្រប់គ្រាន់សម្រាប់ចាប់ផ្ដើមព្យាបាល ហើយផលិតផលធានារ៉ាប់រងបន្ថែម និងផលិតផលធានារ៉ាប់រងមូលដ្ឋានរបស់នាងនៅតែបន្តមានសុពលភាព។



**ករណីទី 2 ៖ កញ្ញា បុប្ផា បានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរ ដូចបានកំណត់ក្រោមជំងឺ/ការវះកាត់ ក្រុមទី 2 ក្នុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង**

កញ្ញា បុប្ផា នឹងទទួលប្រាក់សំណង US$ 50,000 ដកចំណាយណាមួយដែលបានបង់រួច (បើមាន) ផលិតផលធានារ៉ាប់រងបន្ថែមរបស់នាងនឹងត្រូវបានបញ្ចប់ ប៉ុន្តែផលិតផលធានារ៉ាប់រងមូលដ្ឋានរបស់នាងនៅតែបន្តមានសុពលភាព។



**ករណីទី3 ៖ កញ្ញា បុប្ផា ទទួលមរណភាពដោយសារគ្រប់មូលហេតុ (ជំងឺ ឬគ្រោះថ្នាក់) ក្នុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង**

ក្រុមគ្រួសាររបស់ កញ្ញា បុប្ផា នឹងទទួលបានប្រាក់សំណងសរុបចំនួន US$ 100,000 ពីផលិតផលធានារ៉ាប់រងមូលដ្ឋាន។ ហើយផលិតផលធានារ៉ាប់រងបន្ថែម និងផលិតផលធានារ៉ាប់រងមូលដ្ឋានរបស់នាងនឹងត្រូវបានបញ្ចប់។

# តារាងជំងឺធ្ងន់ធ្ងរ

| ជំងឺ/ការវះកាត់ | ការវះកាត់ ក្រុមទី 1 | ការវះកាត់ ក្រុមទី 2 |
|---|---|---|
|  | 1. ជាលិកាមហារីកកកើតនៅទីតាំងដើម (CIS)<br>2. មហារីកក្រពេញប្រូស្តាតដំណាក់កាលដំបូង<br>3. មហារីកក្រពេញទីរ៉ូអ៊ីតដំណាក់កាលដំបូង<br>4. មហារីកប្លោកនោមដំណាក់កាលដំបូង<br>5. មហារីកគ្រាប់ឈាមសរ៉ាំរ៉ៃដំណាក់កាលដំបូង | 14. ជំងឺមហារីក - កម្រិតធ្ងន់ធ្ងរដោយ មិនរាប់បញ្ចូលជំងឺមហារីកដំណាក់កាលដំបូង |
|  | 6. ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬ ឧបករណ៍ភ្ញោចបេះដូង<br>7. ការវះកាត់ព្យាបាលសរសៃឈាម Coronary<br>8. ការវះកាត់ផ្នែកតូចតាចនៃរាងកាយដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅសរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ | 15. ជំងឺគាំងបេះដូង - នៃកម្រិតធ្ងន់ធ្ងរជាក់លាក់<br>16. ការវះកាត់បង្វៀងផ្លូវសរសៃឈាម Coronary Artery<br>17. ការវះកាត់ប្រអប់ទ្រូង ឬប្រអប់ពោះដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅ សរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ |
|  | 9. ការដាក់បំពង់បង្ហូរសារធាតុរាវចេញពីខួរក្បាល (ឧបករណ៍ Shunt) | 18. ជំងឺដាច់សរសៃឈាមខួរក្បាល - ដែលបណ្តាលឲ្យមានការខូចខាតប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងការបន្តនៃរោគសញ្ញា គ្លីនិក |
|  | 10. ការវះកាត់យកសួតមួយចេញ (ក្នុងចំណោមសួតពីរ) | 19. ជំងឺសួតដំណាក់កាលចុងក្រោយ |
|  | 11. ការវះកាត់យកថ្លើមយ៉ាងតិចមួយខ្លែបចេញ (ក្នុងចំណោមប្រាំបីខ្លែប) | 20. ការខូចថ្លើមដំណាក់កាលចុងក្រោយ |
|  | 12. ការវះកាត់យកតម្រងនោមមួយចេញ (ក្នុងចំណោមតម្រងនោមពីរ) | 21. ការខូចតម្រងនោមដំណាក់កាលចុងក្រោយ |
|  | 13. ការផ្លាស់ប្តូរពោះវៀនតូច (ចាប់ពីមួយម៉ែត្រឡើងទៅ) | 22. ការផ្លាស់ប្តូរបេះដូង<br>23. ការផ្លាស់ប្តូរសួត<br>24. ការផ្លាស់ប្តូរថ្លើម<br>25. ការផ្លាស់ប្តូរតម្រងនោម<br>26. ការផ្លាស់ប្តូរលំពែង |

**ការិយាល័យកណ្តាល**

ជាន់ទី 12 អគារ EXCHANGE SQUARE

ផ្លូវលេខ 106 កែងផ្លូវលេខ 61 សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

**សាខាភ្នំពេញ**

ជាន់ទី 8 និងទី 9 អគារ CITY TOWER

លេខ 321 មហាវិថីម៉ៅសេទុង សង្កាត់ផ្សារដេប៉ូ 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ

**សាខាសៀមរាប**

អគារលេខ 29 និង 30

ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6 ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1 ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA




# ADDITIONAL CRITICAL ILLNESS RIDER

We always hope that nothing will happen to us regardless of health or financial issue. However there is no guarantee of tomorrow. We need to be financially prepared for critical illnesses which can drain our saving in a devastating way.

Additional Critical Illness Rider provides you with a lump-sum payment upon diagnosis of up to 26 conditions including cancer, brain, liver, lung, kidney, heart and vascular system diseases from early-stage to late-stage as well as major organ transplantation. With up to 50% of the pay-out starting from early stage, all you need to focus on is the recovery, not the medical bills.

Life Insurance Company

# BENEFIT AT A GLANCE

**The covered events and the corresponding benefit are as illustrated below:**

| Event | of Sum Assured |
|---|---|
| Group 2 Illness/Surgery | 100% |
| Group 1 Illness/Surgery | 50% |

*The aggregate payment made for Group 1 Illness/Surgery and Group 2 Illness/Surgery for an Insured shall not exceed 100% of the Sum Assured for Additional Critical Illness Rider.*

# ELIGIBILITY

- ✓ 18 years old to 60 years old.
- ✓ Purchased a Basic Product from AIA that allows the attachment of this Rider.

# KEY EXCLUSIONS

**This Rider does not cover:**

(i) the signs or symptoms of the Critical Illness Event defined under Group 1 Illness/Surgery is manifested prior to or within 120 days from the Effective Date or Commencement Date of this Rider, whichever is later; or

(ii) the signs or symptoms of the Critical Illness Event defined under Group 2 Illness/Surgery manifested prior to or within 90 days from the Effective Date or Commencement Date of this Rider, whichever is later; or

(iii) the Critical Illness Event arises directly or indirectly from a Pre-Existing Condition as defined, which existed prior to the Effective Date or Commencement Date of this Rider, whichever is later; or

(iv) the Critical Illness Event, where in Our opinion, was caused directly or indirectly by the presence of Acquired Immune Deficiency Syndrome (AIDS) or Human Immunodeficiency Virus (HIV) and any complications thereof; or

(v) any of the Critical Illness Event is caused by a self-inflicted injury; or

(vi) any Critical Illness Event resulting directly from alcohol or drug abuse; or

(vii) any Critical Illness Event resulting from a physical or mental condition which existed before the Effective Date or Commencement Date; or

(viii) donation of any of the Insured's organs.

**This above list is for reference only. Please refer to your Policy Contract for the complete list and details of exclusions.**

## EXAMPLE



Ms. Bopha is a 35-year-old oncologist with parents as dependents. To ensure her parents will not have financial burden should any unfortunate event happens to her, she decides to purchase a basic product with sum assured of US$ 100,000 from AIA.

As an oncologist, she is aware that the treatment cost of cancer and other critical illnesses are high. So she decides to attach a **"Additional Critical Illness Rider"** with sum assured of US$ 50,000.

## BENEFIT PAYABLE TO MS. BOPHA AND HER FAMILY:

**Scenario 1: Ms. Bopha is diagnosed of a Critical Illness Event as defined under Group 1 Illness/Surgery.**

She will receive US$ 25,000 advance payment under this benefit so that she can have sufficient fund to start the necessary treatment. Her Rider and basic product continues.

**Scenario 2: Ms. Bopha is diagnosed of a Critical Illness Event as defined under Group 2 Illness/Surgery.**

She will receive US$ 50,000 less any advance payment made under this rider. The Rider terminates but her basic product continues.

**Scenario 3: Mr. Bopha passes away due to any causes (Sickness or Accident) during the policy term.**

Her family will receive a lump sum of US$ 100,000 from the basic product. Her Rider and basic product terminate.

# CRITICAL ILLNESS TABLE

| Coverage | Group 1 Illnesses/Surgery | Group 2 Illnesses/Surgery |
|---|---|---|
| | 1. Carcinoma in Situ<br>2. Early Prostate Cancer<br>3. Early Thyroid Cancer<br>4. Early Bladder Cancer<br>5. Early Chronic Lymphocytic Leukaemia | 14. Cancer - of specified severity and does not cover very early cancers |
| | 6. Cardiac Pacemaker or Defibrillator Insertion<br>7. Coronary Angioplasty<br>8. Minimally Invasive Surgery to Thoracic or Abdominal Aorta | 15. Heart Attack – of specified severity<br>16. Coronary Artery By-Pass Surgery<br>17. Thoracic or Abdominal Aorta Surgery |
| | 9. Cerebral Shunt Insertion | 18. Stroke – resulting in permanent neurological deficit with persisting clinical symptoms |
| | 10. Surgical Removal of a Lung | 19. Late-Stage Lung Failure |
| | 11. Partial Surgical Removal of the Liver | 20. Late-Stage Liver Failure |
| | 12. Surgical Removal of a Kidney | 21. Late-Stage Kidney Failure |
| | 13. Small Bowel Transplant | 22. Heart Transplantation<br>23. Lung Transplantation<br>24. Liver Transplantation<br>25. Kidney Transplantation<br>26. Pancreas Transplantation |

**HEAD OFFICE**
12TH FLOOR, EXCHANGE SQUARE, STREET 106-61, SANGKAT WAT PHNOM, KHAN DAUN PENH, PHNOM PENH

**PHNOM PENH BRANCH**
8TH & 9TH FLOOR, CITY TOWER, #321, MAO TSE TOUNG BLVD, SANGKAT PHSAR DEPO 1, KHAN TOUL KORK, PHNOM PENH

**SIEM REAP BRANCH**
#29 & 30, CHARLES DE GAULLE ROAD SALA KANSENG, SANGKAT SVAY DONGKOM, SIEM REAP

**BATTAMBANG BRANCH**
HOUSE NO. 2-6, STREET 3, PHUM KAMMEAKAR, SANGKAT SVAY POR, KRONG BATTAMBANG, BATTAMBANG

**KAMPONG CHAM BRANCH**
VILLAGE 15, SANGKAT KAMPONG CHAM, KHAN KAMPONG CHAM, KAMPONG CHAM

**KAMPOT BRANCH**
STREET 700, VILLAGE 1 OSSAPHEA, SANGKAT KAM-PONG KANDAL, KRONG KAMPOT, KAMPOT

086 999 242 | AIA.COM.KH | AIA CAMBODIA